សន្ធិសីទសារព័ត៌មាន
របស់គណបក្ស សម រង្ស៊ី អំពីការផ្តល់សច្ចាប័នចំពោះអនុសញ្ញាបំពេញបន្ថែម
ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនកម្ពុជា-វៀតណាមឆ្នាំ១៩៨៥

ថ្ងៃនេះ សមាជិករដ្ឋសភា ព្រឹទ្ធសភា គណបក្ស សម រង្ស៊ី សំរេចកាន់ទុក្ខចំពោះការបាត់បង់សិទ្ធិរបស់កម្ពុជា លើទឹកដីដែលពួកអាណាព្យាបាលបារាំង និងពួកវៀតណាមឈ្លានពាន បានវាតយកទៅ ហើយបានព្រមព្រៀងដោយអំណាចរណប និងអសមត្ថភាពនៅកម្ពុជានាពេលកន្លងមកនេះ ។

យើងកោតសរសើរ និងគោរពគាំទ្រលោកប្រធាន សម រង្ស៊ី ដែលបានកំណត់ថា អនុសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនកម្ពុជា_វៀតណាមឆ្នាំ១៩៨៥ ជាការខុសច្បាប់ និងធ្វើឲ្យអធិបតេយ្យភាព ប្រណាភាពទឹកដីកម្ពុជាទទួលគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ហើយបានសុំសភា និងទូលសុំព្រះមហាក្សត្រកុំផ្តល់សច្ចាប័នចំពោះអនុសញ្ញាដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ខាយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានចុះហត្ថលេខាកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ នោះ ។ សោកស្តាយណាស់ ដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនផ្តួងផ្តើម មិនជ្រោមជ្រែងក្រុមប្រឹក្សាជាតិជាន់ខ្ពស់កិច្ចការព្រំដែន ដែលមានសមាសភាពពីគ្រប់និន្នាការ និងមានព្រះមហាវីរក្សត្រ នរោត្តម សីហនុ ជីមានកិត្យានុភាពទាំងលើឆាកជាតិ_អន្តរជាតិជាព្រះប្រធានជីកនាំ ។ ផ្ទុយទៅវិញ នាយករដ្ឋមន្ត្រី ហ៊ុន សែន បែរជាអំពាវនាវឲ្យជនកម្ពុជាគ្រប់និន្នាការរួបរួមដោះស្រាយបញ្ហាព្រំដែន របៀបត្រូវតែគាំទ្រអនុសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាឆ្នាំ១៩៨៥ ខុសច្បាប់តែប៉ុណ្ណោះ ។ សមាជិករដ្ឋសភា ព្រឹទ្ធសភា គណបក្ស សម រង្ស៊ី ថ្កោលទោសវិធានការរបស់រាជរដ្ឋាភិបាល និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានប្តឹង និងប្រើប្រព័ន្ធតុលាការឲ្យចាប់អ្នកសំដែងមតិប្រឆាំងចំពោះបញ្ហាព្រំដែនដាក់ពន្ធនាគារក្រោមលេសថា ជាការបរិហារកិត្តិយស ឬញុះញង់ឲ្យមានការប្រឆាំងរាជរដ្ឋាភិបាល និងនាយករដ្ឋមន្ត្រីនោះថា គឺជាអំពើគំរាមបំបាក់មតិប្រជាធិបតេយ្យយ៉ាងផ្តាច់ការ ។ មានការរើសយកចំរៀង និងបង្គាប់ឲ្យប្រព័ន្ធផ្សព្វផ្សាយលើកពីស្តេចលក់ដីឲ្យយួនយៀកកុង ហើយគ្មានទោសទេ ទោះព្រះមហាវីរក្សត្រ នរោត្តម សីហនុ បង្ហើបឲ្យប្តឹងអំពើនោះក៏ដោយ ។ គណបក្ស សម រង្ស៊ី ទាមទារឲ្យដោះលែង និងលើកលែងការដាក់ពន្ធនាគារ ការចោទចាប់កន្លងមកហើយបញ្ឈប់អំពើដូចខាងលើកុំបន្តទៅទៀត ។ មាតុភូមិកម្ពុជាជាអាយុជីវិតរបស់ខ្មែរទាំងអស់គ្នា មេដឹកនាំខ្មែរត្រូវតែប្រមូលយកមតិយោបល់ទាំងឡាយដើម្បីធានាការឯកភាពអំពី អធិបតេយ្យ និងប្រណៈភាពរបស់កម្ពុជា ។ ភាពមិនចុះសម្រុងរវាងព្រះមហាវីរក្សត្រ នរោត្តម សីហនុ និងនាយករដ្ឋមន្ត្រីហ៊ុន សែន អំពីបញ្ហាព្រំដែនកម្ពុជា កាន់តែធ្វើឲ្យពលរដ្ឋកម្ពុជាគ្រប់រូបមានការសង្ស័យ មានការចោទប្រកាន់ចំពោះនាយករដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលដែលបានទៅចរចារព្រមព្រៀង និងចុះហត្ថលេខារបៀបស្ងាត់ៗមិនព្រមបញ្ជាក់ជាមុនអោយបានល្អិតល្អន់ ទូលំទូលាយច្បាស់លាស់ជាក់ស្តែងអំពីផ្នែកច្បាប់ អំពីផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ដោយបង្ហាញផែនទី និងគំនូសព្រំដែនជាមួយការចុះទៅផ្ទៀងផ្ទាត់ជាក់ស្តែងដល់ទីកន្លែង ដើម្បីអោយមជ្ឈដ្ឋាននានាជ្រួតជ្រាប ព្រោះប្រទេសនីមួយៗគេមិនងាយធ្វើអោយ

ស្រេចបាច់ បញ្ចប់ស្រួលៗនូវសិទ្ធិទៅលើទឹកដី ដែលគេមានមូលដ្ឋានច្បាប់អាចតវ៉ាបាននោះឡើយ ។ គណបក្ស សម រង្ស៊ី ផាត់ចោលមតិរដ្ឋាភិបាលដែលចោទអ្នកជំទាស់ រារាំងចំពោះអនុសញ្ញាថា ជាអ្នកប៉ុនប៉ងប្រើកំលាំងដើម្បីដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ឬឆ្លៀតប្រើប្រាស់បញ្ហាព្រំដែននេះដើម្បីបង្កអស្ថេរភាព អសន្តិសុខសំរាប់គោលដៅនយោបាយនោះថា គឺគ្រាន់តែជាការបង្វែងការពិត និងបំភិតបំភ័យដល់អ្នកស្នេហាទឹកដីដ៏ប្លែរផ្តាច់ពិតប្រាកដអោយលែងគិតគូរពីមាតុភូមិតែប៉ុណ្ណោះ ។

សូមកុំដៀងទៅរកអ្នកដទៃ ត្រូវដឹងថាពួកកុម្មុយនីស្តនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងនាយករដ្ឋមន្ត្រីដែលគំរាមជាក់ស្តែង ចង់ប្តូរបបរាជានិយម ទៅជាសាធារណរដ្ឋនិយម បើសភា និងព្រះមហាក្សត្រមិនផ្តល់សច្ចាប័ន ដល់អនុសញ្ញារបស់រដ្ឋាភិបាលពេលនេះ ទើបជាអំពើបង្កអស្ថេរភាពពិតប្រាកដ ។ ការផ្ទេររបស់ចារាំងអាណាព្យាបាលដោយគ្មានការយល់ព្រមពីប្រទេសជាម្ចាស់ទ្វីបកោះតាមខ្សែ Brévier និងការធ្វើ ឬការយល់ព្រមទៅលើសិទ្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ១៩៨៥ ដោយមិនស្ថើភាពក្រោមឥទ្ធិពលបរទេសគ្រប់គ្រងត្រួតត្រាមិនអាចទទួលយកបានឡើយ ។ ចេញពីសន្ធិសញ្ញា អនុសញ្ញាកំណត់ព្រំដែនរវាងកម្ពុជា-វៀតណាមនេះ នាំអោយមានការព្រមព្រៀងរបស់វៀតណាម និងព្រះរាជាណាចក្រថៃឆ្នាំ១៩៩៧ ដែលបណ្តាលអោយមានប្រតិកម្មរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅប្រទេសថៃ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៩ និងប្រតិកម្មរបស់ប្រធានរដ្ឋសភា នរោត្តម រណឫទ្ធិ នៅហាណូយពីថ្ងៃ២៤ ខែឧសភា ឆ្នាំ១៩៩៩ ដែលយើងយល់ថា ទឹកដីកម្ពុជាពិតជាខូចខាតដោយសន្ធិសញ្ញាអនុសញ្ញាខាងលើនេះ ។ ដោយសង្ខេប សមាជិករដ្ឋសភា ព្រឹទ្ធសភា គណបក្ស សម រង្ស៊ី បានជំទាស់ និងមិនយល់ព្រមចំពោះ អនុសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនកម្ពុជា-វៀតណាមឆ្នាំ ១៩៨៥ តាមហេតុផលពីរគឺ :

- គោលការណ៍ច្បាប់អធិបតេយ្យ
- គោលការណ៍ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ប្លែរណភាពទឹកដីជាក់ស្តែង

អនុសញ្ញាបំពេញបន្ថែមនេះ គឺផ្ទុយទៅនឹងស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ និងមិនស្របតាមមាត្រា៥៥នៃរដ្ឋធម្មនុញ្ញាព្រះរាជាណាចក្រកម្ពុជាទីពីរផងដែរ ។

យើងគោរពមាត្រា២រដ្ឋធម្មនុញ្ញាព្រះរាជាណាចក្រកម្ពុជាទី២ ដែលចែងថា "ប្លែរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានជាដាច់ខាត ក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ ។

សូមអោយលោក សុន ឆ័យ បញ្ជាក់ពីស្ថានភាពពិភាក្សាសុំការយល់ព្រមអំពីអនុសញ្ញានៅរដ្ឋសភាបន្ថែម ។

សូមអរគុណ

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥

គង់ គាំ

ប្រធានគណបក្សស្តីទី

សមាជិករដ្ឋសភា ព្រឹទ្ធសភា គណបក្ស សម រង្ស៊ី

សម្រេចការដ៏ទុក្ខ

ចំពោះការបាត់បង់សិទ្ធិរបស់កម្ពុជា លើទឹកដីដែលពួក អាណានិយមបារាំង និងពួកវៀតណាមលួចបាន បានទាត់យកទៅ ហើយបានព្រមព្រៀងដោយអំណាច រណប និងអសមត្ថភាពនៅកម្ពុជានាពេលកន្លងមកនេះ

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥